# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីអំពើយុត្តិធម៌និងអយុត្តិធម៌តាមផ្លូវលោក និងតាមផ្លូវធម៌

**Website: www.hoksavann.org**

ថ្ងៃទី១៨ វិច្ឆិកា ២០០៨

### អំពីអំពើយុត្តិធម៌និងអយុត្តិធម៌តាមផ្លូវលោក

ពាក្យថាយុត្តិធម៌ តាមទស្សនៈរបស់ក្រុមនីតិវិទ្យាក្នុងផ្លូវអាណាចក្រឲ្យន័យថា ភាពត្រឹមត្រូវ ការសមហេតុសមផល ។ ឯពាក្យថាអយុត្តិធម៌មានន័យផ្ទុយគ្នា គឺភាពពុំត្រឹមត្រូវ ភាពពុំសមហេតុផល ។ ភាពត្រឹមត្រូវនិងពុំត្រឹមត្រូវនោះ តាមផ្លូវលោក គឺយោងទៅតាមក្របខណ្ឌនៃច្បាប់របស់ប្រទេសនីមួយៗនិងរបស់អង្គការសហប្រជាជាតិ ដែលគេបានអនុម័តយកមកប្រើ ។ បានសេចក្តីថា យុត្តិធម៌ឬពុំយុត្តិធម៌ស្រេចតែការព្រមព្រៀងគ្នា សន្មត់យកមកអនុវត្ត ។ ក្នុងន័យនេះហើយបានជាគេជ្រើសរើសអ្នកចេះច្បាប់ អ្នកមិនប្រកបដោយអគតិធម៌ បន្ទាប់មកទើបសភាធម្មនុញ្ញ យកសេចក្តីព្រាងនេះទៅពិភាក្សាអនុម័ត ។ លុះសភាធម្មនុញ្ញអនុម័តហើយ គេត្រូវដាក់ឲ្យប្រជាពលរដ្ឋបញ្ចេញមតិលើច្បាប់នោះមួយជាន់ទៀត ។ នេះនិយាយអំពីរបៀបចាត់ចែងបែប្រទេសដែលកាន់របបប្រជាធិបតេយ្យសេរី ។ បើច្បាប់នោះតាក់តែងឡើងដោយជនឬក្រុមផ្តាច់ការ ឬលទ្ធិកុម្មុយនិស្ត ច្បាប់នោះពុំមានយុត្តិធម៌ឡើយ គឺគេតាក់តែងច្បាប់ទៅតាមអំពើផ្តាច់ការរបស់គេ ។ នេះនិយាយអំពីយុត្តិធម៌ ឬពុំយុត្តិធម៌ក្នុងការតាក់តែងនិងអនុវត្តន៍ច្បាប់ ។ ឯការបកស្រាយច្បាប់ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវ គឺជាភារៈរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ដែលបានជ្រើសតាំងពីអ្នកមានចំណេះខាងច្បាប់ ហើយជាស្ថាប័នឯករាជ្យត្រូវបកស្រាយ ឯអ្នកមានអំណាចដែលកាន់នីតិប្រតិបត្តិ មានសិទ្ធិស្មើច្បាប់ដែលគ្មានសិទ្ធិបកស្រាយច្បាប់ឡើយ ។

### អំពីអំពើយុត្តិធម៌និងអយុត្តិធម៌តាមផ្លូវធម៌

ច្បាប់យុត្តិធម៌និងអយុត្តិធម៌ដែលសំដែងឡើងដោយព្រះសម្មាសម្ពុទ្ធជាច្បាប់មានសច្ចធម៌ ជាច្បាប់ធម្មជាតិសកល ។ ពាក្យថាយុត្តិធម៌ស្មើគ្នានិងពាក្យថាអំពើបុណ្យ អំពើជាកុសល និងអំពើសុចរិត ។ ឯពាក្យថាអយុត្តិធម៌ ស្មើគ្នានឹងពាក្យថាអំពើបាប អំពើជាអកុសល និងអំពើទុច្ចរិត ។ ពាក្យទាំងពីរក្រុមនេះផ្ទុយគ្នា ប្រើផ្លាស់ប្តូរគ្នាបាន ។ យុត្តិធម៌ប្រែថាប្រកបដោយធម៌ បានដល់បុណ្យកុសលនិងសុចរិត ឯអយុត្តិធម៌ប្រែថាមិនប្រកបដោយធម៌ បានដល់បាប អកុសល និងទុច្ចរិតនេះឯង ។ បើនិយាយដល់ជំរៅព្រះពុទ្ធសាសនា មូលហេតុដែលនាំឲ្យប្រព្រឹត្តអំពើយុត្តិធម៌និងអយុត្តិធម៌ គឺបើចិត្តបរិសុទ្ធប្រាសចាកលោភៈ ទោសៈ មោហៈ នាំឲ្យនាំឲ្យប្រព្រឹត្តអំពើយុត្តិធម៌ បើចិត្តសៅហ្មង ប្រកបដោយលោភៈ ទោសៈ មោហៈ នាំឲ្យប្រព្រឹត្តអំពើអយុត្តិធម៌ ។ យុត្តិធម៌ជាគុណធម៌ដ៏ខ្ពង់ខ្ពស់នាំឲ្យអ្នកប្រព្រឹត្តបានសុខ ឯអយុត្តិធម៌ជាគុណវិបត្តិ នាំឲ្យអ្នកប្រព្រឹត្តបានទុក្ខ ។ ច្បាប់យុត្តិធម៌និងអយុត្តិធម៌ ដែលរកឃើញដោយព្រះពុទ្ធនេះគឺជាសច្ចសកល ត្រូវគ្រប់ពេលវេលានិងគ្រប់ទីកន្លែង ផ្ទុយគ្នានឹងច្បាប់ផ្លូវលោក ដែលបញ្ញត្តិឡើងតាមការស្រុះស្រួលគ្នាអនុម័ត ពុំអាចមានយុត្តិ-ធម៌ដូចច្បាប់ផ្លូវធម៌ឡើយ ។ បើគេប្រព្រឹត្តល្អដោយកាយវាចាចិត្ត ឈ្មោះថាគេប្រព្រឹត្តអំពើយុត្តិធម៌ បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ឈ្មោះថាគេប្រព្រឹត្តអំពើអយុត្តិធម៌ ។ ដូច្នេះបានសេចក្តីថា អំពើយុត្តិធម៌និងអយុត្តិធម៌នេះ ពុំមែនសំដៅយកតែចៅក្រមកាត់សេចក្តីឡើយ គឺសំដៅយកអំពើល្អនិងអំពើអាក្រក់ជាទូទៅ ។ ព្រះធម៌របស់ព្រះពុទ្ធសាសនាមានយុត្តិធម៌ណាស់ ជាច្បាប់ធម្មជាតិសកល គឺបុគ្គលបានសុខទុក្ខចំរើនវិនាសស្របតាមអំពើរបស់ខ្លួន ។ បានសេចក្តីថា អំពើកម្មរបស់ខ្លួនជាអ្នកកាត់សេចក្តីជាស្វ័យប្រវត្តិ ។ ព្រះពុទ្ធសាសនាសំដែងអំពីទំនាក់ទំនងរវាងហេតុនិងផល គឺហេតុយ៉ាងណាផលក៏យ៉ាងនោះដែរ ។ បានសេចក្តីថា បើហេតុល្អបានផលល្អ បើហេតុអាក្រក់បានផលអាក្រក់ ។ ព្រះពុទ្ធសាសនាបានបញ្ជាក់ទៀតថា ហេតុល្អនិងហេតុអាក្រក់នោះ ទោះបីប្រព្រឹត្តដោយបិទបាំងមិនឲ្យអ្នកដទៃដឹង ក៏នៅតែឲ្យផលនៅពេលណាមួយពុំខានឡើយ ។ តាមពិតសេចក្តីបរិសុទ្ធនិងសៅហ្មង ដែលខ្លួនឯងដឹងដោយខ្លួនឯងនេះហើយ ជាការសំខាន់ ពុំមែនស្ថិតនៅលើអ្នកដទៃដឹង ឬពុំដឹងនោះឡើយ ។៚